**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថា

## របស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការមូលបត្រកម្ពុជា

## និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការ

## “ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (Cambodia Securities Exchange)”

**រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១**

៙៙✸៚៚

- *ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ*
- *ឯកឧត្តម លោកជំទាវ សមាជិក-សមាជិកា នៃរាជរដ្ឋាភិបាលកម្ពុជា*
- *ឯកឧត្តម CHANG Ho-Jin ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា*
- *ឯកឧត្តម KIM Bongsoo ប្រធានអគ្គនាយកនៃក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ*
- *ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ!*

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានទទួលភារកិច្ចដ៏ខ្ពង់ខ្ពស់ពី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មកចូលរួមជាអធិបតីនៅក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ ក្រុមហ៊ុនផ្សារមូលបបត្រកម្ពុជា (CSX) នាឱកាសនេះ។

ថ្ងៃនេះគឺជាថ្ងៃប្រវត្តិសាស្ត្រដ៏សំខាន់មួយនៃវិស័យហិរញ្ញវត្ថុ និងជាមោទនភាពជាតិមួយ សម្រាប់កម្ពុជា ដែលនៅទីបំផុត ទីផ្សារមូលបត្រមួយបានស្ថិតក្នុងដំណាក់កាលចុងក្រោយនៃការលេចជារូបរាងឡើង ។ នេះបង្ហាញឱ្យឃើញថា ប្រទេសកម្ពុជាកំពុងឈានចូលដល់ដំណាក់កាលថ្មីមួយនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ស្របតាម **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥"** និង **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២** របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមចក្ខុវិស័យដឹកនាំជាប្រចាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**។

យោងតាមយុទ្ធសាស្ត្រទាំងពីរខាងលើ ការបង្កើតទីផ្សារមូលបត្រនេះមានសារៈសំខាន់ សម្រាប់ក្រុមហ៊ុននានា ក៏ដូចជាសម្រាប់សេដ្ឋកិច្ចជាតិទាំងមូល តាមរយៈ ÷ ១)ការលើកកម្ពស់អភិបាលកិច្ចសាជីវកម្ម, ២) ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងក្រុមហ៊ុន ដោយការមានយន្តការច្បាស់លាស់ក្នុងការគ្រប់គ្រងហានិភ័យ ការមានគណនេយ្យភាពនិងតម្លាភាពក្នុងកិច្ចការអាជីវកម្ម និងការប្រកាន់ខ្ជាប់នូវក្រមវិជ្ជាជីវៈច្បាស់លាស់ ដែលជាបុរេលក្ខខណ្ឌសម្រាប់ការទាក់ទាញទុនរយៈពេលវែង ពីសាធារណជន ទាំងក្នុងនិងក្រៅប្រទេស សម្រាប់ពង្រីកអាជីវកម្ម និងពង្រឹងលទ្ធភាពប្រកួតប្រជែងក្នុងទីផ្សារជាតិនិងអន្តរជាតិ, ៣) Last but not least ការផ្តល់នូវជម្រើសមួយទៀតដល់សាធារណជន ក្នុងការសន្សំប្រាក់ និងការវិនិយោគ ។

ការសម្ពោធនៅថ្ងៃនេះ គឺជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ (KRX) ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX) ក្រុមហ៊ុនមូលបត្រ ក៏ដូចជាស្ថាប័នពាក់ព័ន្ធដទៃទៀត រួមទាំងវិស័យឯកជន ប្រទេសជាមិត្ត និងដៃគូអភិវឌ្ឍន៍ ក្នុងការចូលរួមយ៉ាងសកម្មធ្វើឱ្យសម្រេចបាននូវការត្រៀមលក្ខណៈជាស្រេចទាំងផ្នែកគតិយុត្ត ធនធានមនុស្ស និងបច្ចេកទេស ដើម្បីឱ្យទីផ្សារមូលបត្រអាចដំណើរការបានដោយពេញលេញ នៅចុងឆ្នាំនេះ ។ ទីផ្សារមូលបត្រដែលមានដំណើរការពេញលេញ

មានន័យថាក្រុមហ៊ុនដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ បានធ្វើការលក់មូលបត្ររបស់ខ្លួនក្នុងទីផ្សារដំបូង (Primary Market) ឬហៅថា IPO (Initial Public Offering) និងបន្ទាប់មកមូលបត្រទាំងនោះត្រូវបានយកទៅចុះបញ្ជីសម្រាប់ការជួញដូរ ឬទិញលក់បន្ត នៅក្នុងទីផ្សារបន្ទាប់ (Secondary Market) នៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាកម្មវត្ថុនៃការសម្ពោធនៅថ្ងៃនេះ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវមូលវិចារណ៍ដ៏ថ្លៃថ្លា ចំពោះគណៈគ្រប់គ្រងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX) ដែលមាន ÷ ឯកឧត្តម **ហ៊ាន សាហ៊ីប** ជាប្រធានក្រុមប្រឹក្សាភិបាល លោក **ហុង សុហួរ** ជាអគ្គនាយក និងលោក **មីន យ្យុងហ៊ួន** (MIN Kyoung-Hoon) ជាអគ្គនាយករងព្រមទាំងបុគ្គលិកទាំងអស់ ដែលបានខិតខំប្រឹងប្រែង ប្រកបដោយសេចក្តីព្យាយាមខ្ពស់ ដើម្បីអាចឈានដល់ការដាក់សម្ពោធនៅថ្ងៃនេះ រួមទាំងការសិក្សារៀបចំនូវវិធានផ្សេងៗរបស់ក្រុមហ៊ុនផងដែរ នាពេលកន្លងមក។ ហើយទន្ទឹមនឹងនេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមប្រធាន-អគ្គនាយក KIM Bong-Soo និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ (Korea Exchange - KRX) ដែលបានផ្តល់ការជ្រោមជ្រែងនិងកិច្ចសហប្រតិបត្តិការល្អ ជារៀងរហូតមក ទាំងផ្នែកបណ្តុះបណ្តាលធនធានមនុស្ស និងផ្នែកបច្ចេកទេស ដល់បណ្តាស្ថាប័នសាធារណៈក៏ដូចជាឯកជន ដែលបម្រើការក្នុងឬពាក់ព័ន្ធនឹងវិស័យមូលបត្រ ។ លើសពីនេះ ខ្ញុំសូមសំដែងជាឧឡារិកនូវមូលវិចារណ៍ដោយឡែកមិនអាចកាត់ថ្លៃបានចំពោះ **បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន** ក្នុងឋានៈជានិម្មាបនិក ពោរពេញទៅដោយគំនិតច្នៃប្រឌិត និងស្មារតីស៊ូទ្រាំ កសាងបាននូវផ្សារមូលបត្រកម្ពុជា ដែលកំពុងលេចរូបរាងច្បាស់ឡើងនៅពេលនេះ ។

***ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី!***

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គឺជាសហគ្រាសសាធារណៈ ដែលជាសមិទ្ធផលរួមគ្នារវាងរាជ-រដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ ដែលក្នុងនោះ រាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាន់កាប់ចំនួន ៥៥% និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ កាន់កាប់ចំនួន ៤៥% ។ គួររំលឹកផងដែរថា ដើម្បីឈានមកដល់ការបង្កើតក្រុមហ៊ុនចំរុះនេះ ចំណុចចាប់ផ្តើមបានកើតឡើងតាមរយៈការចុះអនុស្សារណៈយោគយល់គ្នា

រវាងរូបខ្ញុំតំណាងឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា និងឯកឧត្តម ដុក ស៊ូ ហាន់ (Duck-Soo Han) ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងសេដ្ឋកិច្ចកូរ៉េ នៅថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០០៦ នៅទីក្រុង Hyderabad ប្រទេសឥណ្ឌា ក្នុងឱកាសប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុ នៃអាស៊ាន+៣ ទល់គ្នានឹងការប្រជុំ ADB ប្រចាំឆ្នាំ ។ បន្ទាប់មក នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ការចុះអនុស្សារណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការក្នុងការបង្កើតទីផ្សារមូលបត្រ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ និងនៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៨ ការចុះអនុស្សារណៈយោគយល់គ្នាស្តីពីការសម្រេចជ្រើសរើសយកក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ ជាដៃគូយុទ្ធសាស្ត្រតែមួយគត់នៅក្នុងគម្រោងបង្កើតទីផ្សារមូលបត្រ មុននឹងឈានដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (Joint-Venture Agreement on the Establishment of the Cambodia Securities Exchange Co., Ltd) នៅថ្ងៃទី ២៣ ខែមិនា ឆ្នាំ ២០០៩ ។

គួរបញ្ជាក់ដែរថា ការបង្កើតក្រុមហ៊ុនចំរុះនេះឡើងត្រូវបានទទួលការយកចិត្តទុកដាក់ខ្ពស់ ពីប្រមុខដឹកនាំ នៃប្រទេសទាំងពីរ កម្ពុជា និងកូរ៉េ ។ ជាមួយគ្នានេះ រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ក៏បានផ្តល់ជំនួយបច្ចេកទេស តាមរយៈភ្នាក់ងារអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍កូរ៉េ (KOICA) សម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញមូលបត្រ ដល់មន្ត្រីជំនាញកម្ពុជា ពិសេសមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងក្រុមហ៊ុនរដ្ឋ ដែលកំពុងត្រៀមខ្លួនបំពេញនីតិវិធីនៃការបោះផ្សាយលក់មូលបត្រនាពេលដ៏ខ្លីខាងមុខ ។ ឆ្លៀតក្នុងឱកាសនេះ តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជា ខ្ញុំសូមសម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះរដ្ឋាភិបាលកូរ៉េ ក៏ដូចជាប្រជាជនកូរ៉េ ដែលបានផ្តល់ជំនួយបច្ចេកទេសសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា ក៏ដូចជាផ្តល់ហិរញ្ញប្បទាន សហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ (ODA) ផ្សេងៗ ដល់កម្ពុជា ក្នុងការកសាង និងស្តារហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់កម្ពុជា នាពេលកន្លងមក រួមទាំងការជំរុញការវិនិយោគឯកជនកូរ៉េមកកម្ពុជាផងដែរ ។

*ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី!*

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាគឺជាតួអង្គស្នូលនៅក្នុងទីផ្សារបន្ទាប់ ដែលដើរតួនាទីជាអន្តរការីរវាង ក្រុមហ៊ុនមូលបត្រជាសមាជិក ដែលជាភ្នាក់ងាររបស់វិនិយោគិនក្នុងការទិញ/លក់មូលបត្រ នៅក្នុង

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ។ ការសម្ពោធដាក់ឱ្យដំណើរការនាថ្ងៃនេះជាសក្ខីភាពបង្ហាញថា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាត្រៀមខ្លួនរួចជាស្រេចក្នុងការទទួលឱ្យមានការជួញដូរមូលបត្រ ដែលគ្រោងនឹងចាប់ផ្តើមនៅចុងឆ្នាំនេះ បើតួអង្គក្រុមហ៊ុនបោះផ្សាយលក់មូលបត្រដែលជាសហគ្រាសរដ្ឋ អនុវត្តការងារបានតាមការគ្រោងទុក ដោយអនុលោមតាមបទប្បញ្ញត្តិនៅក្នុងវិស័យមូលបត្រជាធរមាន ។ ក្នុងនាមជាអាណាព្យាបាលហិរញ្ញវត្ថុរបស់សហគ្រាសរដ្ឋ ខ្ញុំសូមយកឱកាសនេះជម្រាបជូនដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាជ្រាបថា សហគ្រាសរដ្ឋទាំងបីដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ បាននិងកំពុងធ្វើការយ៉ាងមមាញឹក ក្នុងការបំពេញនីតិវិធីនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដើម្បីឈានទៅដល់ការចុះបញ្ជីសម្រាប់ជួញដូរនៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ។ ហើយឆ្លៀតឱកាសនេះ ខ្ញុំសូមស្នើឱ្យគណៈគ្រប់គ្រង និងមន្ត្រី-បុគ្គលិករបស់សហគ្រាសសាធារណៈទាំងបី ព្រមទាំងភាគីដែលពាក់ព័ន្ធទាំងអស់ត្រូវខិតខំ កាន់តែខ្លាំងថែមទៀត ដើម្បីឱ្យការបោះផ្សាយលក់មូលបត្រអាចប្រព្រឹត្តទៅ តាមពេលវេលាដែលបានគ្រោងទុក ។

ជាថ្មីម្តងទៀត តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម KIM Bongsoo ប្រធានអគ្គនាយកនៃក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ ដែលបានធ្វើដំណើរពីសាធារណរដ្ឋកូរ៉េ អញ្ជើញចូលរួមពិធីសម្ពោធនាថ្ងៃនេះ ដែលការណ៍នេះញ៉ាំងឱ្យពិធីសម្ពោធនេះ កាន់តែមានអត្ថន័យ និងឆ្លុះបញ្ចាំងពីការប្តេជ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ (KRX) ក្នុងការបង្កើតនិងអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមរដ្ឋមន្ត្រី ឯកឧត្តមអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េ ព្រមទាំងឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ទាំងអស់ ដែលបានចំណាយពេលវេលាដ៏មមាញឹកអញ្ជើញចូលរួម ក្នុងពិធីសម្ពោធនាថ្ងៃនេះ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឱ្យក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ប្រកបអាជីវកម្មដោយជោគជ័យរុងរឿងរីកចម្រើនទៅថ្ងៃមុខ ដោយត្រូវយកចិត្តទុកដាក់ខ្ពស់ដល់ការរៀបចំនិងបង្កើតយន្តការកសាងទំនុកចិត្តរបស់សាធារណជន ទាំងជាតិ និងអន្តរជាតិ ដើម្បីជាប្រយោជន៍នៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងសេដ្ឋកិច្ចកម្ពុជា និងសូមប្រសិទ្ធិពរជូនចំពោះឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ សិរីមង្គល វិបុលសុខ និងជោគជ័យគ្រប់ភារកិច្ច-ធុរកិច្ច ។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំ រួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ដែលមានវត្តមាននៅទីនេះ **សូមប្រកាសបើកសម្ពោធជាផ្លូវការក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចាប់ពីពេលនេះតទៅ ។**

សូមអរគុណ !